# លក្ខន្តិកៈទូទៅស្តីពីការជ្រើសរើសសិក្ខាកាម

## សិក្ខាសាលាស្តីពីការលើកកំពស់ជំនាញវាយនភណ្ឌ និង នវានុវត្តន៍ទន្លេមេគង្គ-ឡានឆាងឆ្នាំ2023 របស់គម្រោងវេទិកាយុនមីងកិច្ចសហប្រតិបត្តិការអប់រំអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍លើកទី6 តម្បាញសម្រេចក្តីស្រមៃដែនដីមាតុភូមិដ៏ស្រស់ស្អាត (រោងជាងបេតិកភណ្ឌវប្បធម៌អរូបីទន្លេមេគង្គ-ឡានឆាងរបស់សាកលវិទ្យាល័យជាតិយូណាន)

### 1. ប្រវត្តិនៃការអនុវត្តគម្រោង

តំបន់អាងទន្លេមេគង្គ-ឡានឆាងសម្បូរទៅដោយធនធានវប្បធម៌អរូបី។ ដើម្បីពង្រឹងការការពារមរតក និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការនៃបេតិកភណ្ឌវប្បធម៌អរូបីជាតិក្នុងតំបន់ ក្រោមការគាំទ្រពីមូលនិធិពិសេសកិច្ចសហប្រតិបត្តិការអាស៊ីរបស់ក្រសួងអប់រំ សាកលវិទ្យាល័យជាតិយូណានបានប្រើប្រាស់ "រោងជាងបេតិកភណ្ឌវប្បធម៌អរូបីទន្លេមេគង្គ-ឡានឆាង" ជាវេទិកាប្រារព្ធសិក្ខាសាលាស្តីពីការលើកកំពស់ជំនាញវាយនភណ្ឌនិងនវានុវត្តន៍ទន្លេមេគង្គ-ឡានឆាងឆ្នាំ2023 សម្រាប់បណ្តាប្រទេសទាំងប្រាំមួយនៅតាមបណ្តោយអាងទន្លេ។

សិក្ខាសាលាលើកនេះបានចាប់ផ្តើមជាមួយនឹងជំនាញវាយនភណ្ឌ ធ្វើការផ្លាស់ប្តូរជំនាញនិងលើកកំពស់មនោគតិក្នុងការប៉ាក់ ការត្បាញ ការបោះពុម្ព និងការ

ជ្រលក់ពណ៌តាមបណ្ដាប្រទេសអាងឆ្នេរទាំងប្រាំមួយ បង្កើតជាច្រកផ្លាស់ប្ដូរនិងវេទិកាសម្រាប់ការការពារមរតក និងការពារសិប្បកម្មវប្បធម៌ប្រពៃណីរបស់ជនជាតិភាគតិចតាមទន្លេមេគង្គ-ឡានឆាង។ គម្រោងនេះត្រូវបានមន្ទីរអប់រំខេត្តយូណានបញ្ចូលក្នុងគម្រោងនៃ "វេទិកាយុនមីងកិច្ចសហប្រតិបត្តិការអប់រំអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍លើកទី6"។

## 2. ការណែនាំអំពីអង្គភាពសំខាន់ៗ

សាកលវិទ្យាល័យជាតិយូណានគឺជាសាកលវិទ្យាល័យចម្រុះមួយដែលបណ្ដុះបណ្ដាលអ្នកជំនាញជាន់ខ្ពស់គ្រប់ជាតិសាសន៍ ជាសាកលវិទ្យាល័យដ៏សំខាន់មួយថ្នាក់ខេត្តដែលរួមគ្នាបង្កើតឡើងដោយក្រសួងអប់រំ គណៈកម្មការជាតិសាសន៍ថ្នាក់ជាតិ និងរដ្ឋាភិបាលប្រជាជនខេត្តយូណាន។ សាលាបានបង្កើតឡើងនៅថ្ងៃទី1 ខែសីហា ឆ្នាំ1951 ជាមហាវិទ្យាល័យ និងសកលវិទ្យាល័យជាតិកម្រិតខ្ពស់ដំបូងបំផុតមួយរបស់សាធារណៈរដ្ឋប្រជាមានិតចិន មកទល់បច្ចុប្បន្នមានប្រវត្តិ72 ឆ្នាំហើយ។ សាលាមាននិស្សិតថ្នាក់បរិញ្ញាបត្រ អនុបណ្ឌិត បណ្ឌិត និងនិស្សិតអន្តរជាតិសរុបប្រមាណ 3.4ម៉ឺននាក់ បានក្លាយជាសាកលវិទ្យាល័យចម្រុះមួយដែលមានមុខជំនាញពេញលេញ ការអប់រំមានលក្ខណៈពិសេសលេចធ្លោ គ្របដណ្ដប់លើ10មុខជំនាញវិជ្ជាជីវៈដូចជាទស្សនវិជ្ជា សេដ្ឋកិច្ច នីតិសាស្ត្រ អប់រំ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ វិស្វកម្ម គ្រប់គ្រង និងសិល្បៈជាដើម បង្កើតបានជាសក្ដានុពលពិសេសនៃជាតិពន្ធុវិទ្យា សង្គមវិទ្យា ភាសានិងអក្សរសាស្ត្រជនជាតិភាគតិច ភាសាវប្បធម៌អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង ផ្ដោតសំខាន់ទាំងវប្បធម៌និងវិទ្យាសាស្ត្រ សណ្ឋានមុខជំនាញវិជ្ជាជីវៈជាច្រើនអភិវឌ្ឍស្របគ្នា។

សាលាយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយពិភពខាងក្រៅ ជាច្រកដ៏សំខាន់សម្រាប់ប្រទេសចិន និងខេត្តយូណានក្នុងការបើកចំហ

ទៅកាន់ពិភពខាងក្រៅ។ ចាប់តាំងពីការបង្កើតសាលាមក មានប្រមុខរដ្ឋមកពីជាង 80ប្រទេសនិងតំបន់ដូចជា ព្រះមហាក្សត្រិយានី អេលីហ្សាបែតទី 2 របស់ចក្រភពអង់គ្លេស លោកបណ្ឌិត ហេនរី គីស៊ីនជ័រ អតីតរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ព្រះមហាក្សត្រ ហាក៉ុលទី5 របស់ប្រទេសន័រវេស និងលោកប្រធានហូជីមិញ របស់ប្រទេសវៀតណាមជាដើម អ្នកនយោបាយ អ្នកជំនាញ អ្នកប្រាជ្ញ និងមិត្តអន្តរជាតិបានមកធ្វើទស្សនកិច្ចនៅសាកលវិទ្យាល័យជាតិយូណានជាង 10ម៉ឺនលើក និងធ្វើការវាយតម្លៃល្អ។

## 3. វិធីសាស្ត្រ និងខ្លឹមសារនៃសិក្ខាសាលា

គម្រោងនេះគ្រោងនឹងធ្វើឡើងក្នុងអំឡុងខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ2023 ការបណ្តុះបណ្តាលមានរយៈពេលថ្ងៃ10។ ការរៀបចំការបណ្តុះបណ្តាលធ្វើការកំណត់ជាបណ្តោះអាសន្នដូចខាងក្រោម៖

ដំណាក់កាលទីមួយ៖ ការជ្រើសរើសសិក្ខាកាមចូលរៀន។ ចាប់ពីថ្ងៃទី 10 ខែសីហា ដល់ថ្ងៃទី 20 ខែកញ្ញា ឆ្នាំ 2023 ធ្វើការងារផ្សព្វផ្សាយ ជ្រើសរើសសិក្ខាកាម និងចេញលិខិតអញ្ជើញ។

ដំណាក់កាលទីពីរ៖ ការត្រៀមលក្ខណៈដំណាក់កាលដំបូង។ ចាប់ពីថ្ងៃទី 20 ខែកញ្ញា ដល់ថ្ងៃទី 10 ខែវិច្ឆិកា ឆ្នាំ 2023 សិក្ខាកាមធ្វើលិខិតឆ្លងដែន ទិដ្ឋាការជាដើម បំពេញនីតិវិធីឆ្លងដែនចូលក្នុងប្រទេសចិន និងត្រៀមផលិតផលសិប្បកម្មមួយឈុតដែលត្រូវនាំយកទៅសិក្ខាសាលាដើម្បីផ្លាស់ប្តូរ និងបង្ហាញ (ផលិតផលសិប្បកម្មនេះអាចជាផលិតផលសម្រេច ឬពាក់កណ្តាលសម្រេច ធ្វើការកែលម្អក្នុងកំឡុងពេលសិក្ខាសាលាក្រោមការណែនាំរបស់អ្នកជំនាញ) ។

ដំណាក់កាលទីបី៖ ចាប់ពីថ្ងៃទី11 ខែវិច្ឆិកាដល់ថ្ងៃទី 14 ខែវិច្ឆិកាឆ្នាំ 2023 ប្រារព្ធពិធីបើក និងរៀនជុំគ្នានៅសាកលវិទ្យាល័យជាតិយូណាន ទីក្រុងឃុនមីង ខេត្តយូណាន ប្រទេសចិន។ វគ្គសិក្សាសំខាន់ៗ៖ "ការជ្រៀតចូលនៃសិល្បៈជនជាតិក្នុងការរស់ឡើងវិញនូវវប្បធម៌ជនបទ" "ការសិក្សាសិល្បៈនៃការអនុវត្តការជ្រលក់ពណ៌" "ការអនុវត្តគំនិតរចនានិងច្នៃប្រឌិត" "តំណាងវប្បធម៌ក្នុងសិល្បៈសិប្បកម្មសំ

សៀកបំពាក់" "ការផ្លាស់ប្តូរការបង្ហាញស្នាដៃទាយាទជំនាញវាយនភណ្ឌ" "ការរចនារូបភាពនៃបេតិកភណ្ឌវប្បធម៌អរូបី" ជាដើម។

ដំណាក់កាលទីបួនៈ ចាប់ពីថ្ងៃទី 15 ខែវិច្ឆិកា ឆ្នាំ 2023 ដល់ថ្ងៃទី 17 ខែវិច្ឆិកា ឆ្នាំ 2023 ទៅមហាវិទ្យាល័យវិនសានដើម្បីអនុវត្ត និងផ្លាស់ប្តូរជំនាញប៉ាក់ជនជាតិជ័ង សិប្បកម្មសំលៀកបំពាក់ជនជាតិអ៊ី និងសិប្បកម្មបាទីកជនជាតិមែវ។

ដំណាក់កាលទីប្រាំៈ ថ្ងៃទី18 ខែវិច្ឆិកា ឆ្នាំ2023 សិក្ខាកាមទំនាក់ទំនងជាមួយគ្រូបង្វឹករបស់ពួកគេ និងទទួលបានការណែនាំពីអ្នកជំនាញ ហើយចុងក្រោយបញ្ចប់ការធ្វើផលិតផលសិប្បកម្មវាយនភណ្ឌ។ ស្នាដៃទាំងនោះនឹងត្រូវ"រោងជាងបេតិកភណ្ឌវប្បធម៌អរូបីទន្លេមេគង្គ-ឡានឆាង" ធ្វើការរក្សាទុក ហើយចេញវិញ្ញាបនបត្ររក្សាទុក។

ដំណាក់កាលទីប្រាំមួយៈ នៅថ្ងៃទី 19 ខែវិច្ឆិកា ឆ្នាំ 2023 ការតាំងពិពណ៌ស្នាដៃសិក្ខាកាមនឹងប្រព្រឹត្តឡើងនៅតំបន់ពាណិជ្ជកម្មសេរីសាកល្បង(យូណាន)ចិន ប្លុកយុនមីង សួនវប្បធម៌និងច្នៃប្រឌិតសិនលី។

## 4. ក្រុមសាស្ត្រាចារ្យ

គម្រោងនេះពឹងផ្អែកទៅលើធនធានអប់រំ និងសាស្ត្រាចារ្យឈានមុខគេនៃមហាវិទ្យាល័យវិជ្ជាជីវៈអន្តរជាតិមេគង្គ-ឡានឆាងរបស់សាកលវិទ្យាល័យជាតិយូណាន ប្រមូលផ្តុំទៅដោយសាស្ត្រាចារ្យ អ្នកជំនាញសិល្បៈល្បីៗមកពីទាយាទមរតកវប្បធម៌អរូបីថ្នាក់ជាតិ មហាវិទ្យាល័យវិចិត្រសិល្បៈឈីងហ័រ សាកលវិទ្យាល័យតុងហ័រ សាកលវិទ្យាល័យវិចិត្រសិល្បៈយូណាន មហាវិទ្យាល័យវិនសាន មហាវិទ្យាល័យវិចិត្រសិល្បៈក្វាងស៊ីជាដើម នឹងផ្តល់បទពិសោធវគ្គសិក្សាដ៏ល្អបំផុតដល់សិក្ខាកាម។

## 5. បទបញ្ញត្តិស្តីពីការដាក់ពិន្ទុ

ការដាក់ពិន្ទុគឺផ្តោតសំខាន់លើការវាយតម្លៃគុណភាពនៃការបញ្ចប់វគ្គសិក្សារបស់សិក្ខាកាម។ ស្តង់ដារដាក់ស្តែង (គិតជាភាគរយ)៖ វត្តមានមានចំនួន 20% ដំណាក់កាលច្នៃបង្កើត (គំនូរព្រាង គ្រោងការណ៍ ការបង្ហាញ។ ល។ ) មានចំនួន

30% ស្នាដៃចុងក្រោយដែលបានបង្កើតមានចំនួន 30% ការចូលរួមក្នុងការតាំងពិពណ៌មានចំនួន 20%។ បន្ទាប់ពីឆ្លងកាត់ការវាយតម្លៃ និងការពិនិត្យសម្រេចថាជាប់រួច អ្នកអាចទទួលបាន "វិញ្ញាបនបត្របញ្ចប់ការសិក្សា" ដែលចេញដោយសាកលវិទ្យាល័យជាតិយូណាន។

## 6. ការជ្រើសរើសសិស្សចូលរៀន

គម្រោងនេះអនុវត្តតាមគោលការណ៍បើកចំហ យុត្តិធម៌ និងអព្យាក្រឹតក្នុងការជ្រើសរើសនិស្សិតមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ ទទួលយកការដាក់ពាក្យជាលក្ខណៈបុគ្គល ពិនិត្យវាយតម្លៃដោយអ្នកជំនាញ និងជ្រើសរើសសិក្ខាកាមឆ្នើមឲ្យចូលរៀនដោយផ្អែកលើគុណសម្បត្តិសម្រាប់ការជ្រើសរើស ហើយចុងក្រោយជ្រើសរើសសិក្ខាកាមចំនួន 20 នាក់។ សិក្ខាកាមដែលត្រូវបានជ្រើសរើសគឺជាសិប្បករដែលទាក់ទងនឹងវិស័យវាយនភណ្ឌ ឬអ្នកមានទេពកោសល្យសិល្បៈវ័យក្មេង និងវ័យកណ្តាល ដែលសម្រេចបានសមិទ្ធផលមួយចំនួនក្នុងការស្រាវជ្រាវទាក់ទងនឹងវាយនភណ្ឌ ហើយអាយុរបស់ពួកគេគឺមិនលើសពី 55 ឆ្នាំ។ ចំពោះអ្នកដែលមានទឹកដៃសិប្បកម្មឈានមុខគេទាក់ទងនឹងវិស័យវាយនភណ្ឌត្រូវបានផ្តល់អាទិភាព។ ចំពោះអ្នកដែលមានសមត្ថភាពទាក់ទងរហូតដល់អាចបង្រៀនជំនាញដល់អ្នកដែលទើបតែចូលប្រកបវិជ្ជាជីវៈក្នុងវិស័យវាយនភណ្ឌប្រទេសរបស់ខ្លួនបន្ទាប់ពីទទួលការបណ្តុះបណ្តាលត្រូវបានផ្តល់អាទិភាព។ ស្ត្រីត្រូវបានផ្តល់អាទិភាព។ (ប្រសិនបើអ្នកមានជំងឺទូទៅត្រូវទាក់ទងជាមួយអ្នករៀបចំជាមុនដើម្បីកំណត់ថាតើអ្នកអាចចូលរួមក្នុងវគ្គបណ្តុះបណ្តាលបានដែរឬទេ)។

## 7. ការចំណាយលើការបណ្តុះបណ្តាល

គម្រោងនេះត្រូវបានឧបត្ថម្ភដោយមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការទ្វីបអាស៊ីរបស់ក្រសួងអប់រំ មូលនិធិរោងជាងបេតិកភណ្ឌវប្បធម៌អរូបីទន្លេមេគង្គ-ឡានឆាង និងមូលនិធិវៃអេង្គាសប្រាក់ដោយផ្ទាល់ខ្លួនរបស់មហាវិទ្យាល័យវិនសាន។ ការចំណាយលើការធ្វើដំណើរទៅមកក្នុងកំឡុងពេលបណ្តុះបណ្តាលនៅប្រទេសចិន ការចំណាយលើអាហារនិងកន្លែងស្នាក់នៅក្នុងអំឡុងពេលបណ្តុះបណ្តាល និងការចំណាយលើការសិក្សារបស់សិក្ខាកាមដែលចូលរួមការបណ្តុះបណ្តាលជាបន្ទុករបស់គម្រោង។ ការចំណាយធ្វើលិខិតឆ្លងដែន និងទិដ្ឋាការជាបន្ទុករបស់សិក្ខាកាម។

## 8. វិធីចុះឈ្មោះ

(1) សូមសិក្ខាកាមដែលមានបំណងចុះឈ្មោះចូលរៀនបំពេញតារាងចុះឈ្មោះ ហើយបញ្ជូនតារាងចុះឈ្មោះ និងរូបថតផលិតផលតំណាងរបស់ខ្លួនទៅកាន់អាសយដ្ឋានអ៊ីមែល ynmdlmxy@ymu.edu.cn ឲ្យបានមុនថ្ងៃទី 20 ខែកញ្ញា ឆ្នាំ 2023។ ចំណាំ៖ ណែនាំឱ្យបំពេញតារាងចុះឈ្មោះតាមទម្រង់អេឡិចត្រូនិក ប្រសិនបើអ្នកសរសេរដោយដៃ សូមប្រាកដថាការសរសេរដោយដៃមានអក្សរច្បាស់។

(2) សិក្ខាកាមត្រូវត្រៀមសម្ភារៈផលិតផលសម្រេចឬពាក់កណ្តាលសម្រេចទាក់ទងនឹងវាយនភណ្ឌមុនវគ្គបណ្តុះបណ្តាល ដើម្បីជាការរៀបចំដាក់បង្ហាញរក្សាទុកសមិទ្ធផលរបស់គម្រោង។

(3) សម្រាប់ការប្រឹក្សាការចុះឈ្មោះ សូមទាក់ទងគណៈកម្មាធិការរៀបចំតាមរយៈ ynmdlmxy@ymu.edu.cn ។

(4) សម្រាប់ព័ត៌មានលម្អិតសូមស្វែងរកនៅលើ http://ynat.ynni.edu.cn/web/74817/showartical?ArticalId=98ccf065-3996-47e7-a1e1-c68d496c8e50

អាចទាញយកតារាងដែលពាក់ព័ន្ធនឹងការចុះឈ្មោះ

# តារាងចុះឈ្មោះសិក្ខាសាលាពីការលើកកំពស់ជំនាញវាយនភណ្ឌ និងនវានុវត្តន៍ទន្លេមេគង្គ-ឡានឆាងឆ្នាំ2023 រោងជាងបេតិកភណ្ឌវប្បធម៌អរូបីទន្លេមេគង្គ-ឡានឆាងរបស់សាកលវិទ្យាល័យជាតិយូណាន

<table>
<tr><td>គោត្តនាម និងនាម</td><td></td><td>ភេទ</td><td></td><td>ថ្ងៃខែឆ្នាំ<br>កំណើត</td><td></td><td rowspan="2">រូបថតបុគ្គល</td></tr>
<tr><td>កម្រិតវប្បធម៌ខ្ពស់បំផុត</td><td></td><td>មុខជំនាញ</td><td></td><td>មុខរបរ</td><td></td></tr>
<tr><td>លេខលិខិតឆ្លងដែន</td><td colspan="3"></td><td>អ៊ីមែល</td><td colspan="2"></td></tr>
<tr><td>អង្គភាពការងារ/សិក្សា</td><td colspan="3"></td><td>លេខទូរស័ព្ទ</td><td colspan="2"></td></tr>
<tr><td>ជំនាញពិសេសផ្នែក<br>សិប្បកម្ម</td><td colspan="6"></td></tr>
<tr><td>បទពិសោធន៍ពាក់ព័ន្ធ<br>នឹងការងារសិល្បៈវប្ប<br>ធម៌</td><td colspan="6"></td></tr>
<tr><td>ការពណ៌នាអំពីកម្រិត<br>សមត្ថភាពភាសា<br>បរទេស</td><td colspan="6">ភាសាអង់គ្លេស ☐ល្អណាស់ ☐ស្ទាត់ជំនាញ ☐អ្នករៀនថ្នាក់ដំបូង ☐មិនចេះទាល់តែសោះ<br>ភាសាចិន ☐ល្អណាស់ ☐ស្ទាត់ជំនាញ ☐អ្នករៀនថ្នាក់ដំបូង ☐មិនចេះទាល់តែសោះ<br>ភាសាដទៃទៀត ____________________<br>☐ល្អណាស់ ☐ស្ទាត់ជំនាញ ☐អ្នករៀនថ្នាក់ដំបូង ☐មិនចេះទាល់តែសោះ</td></tr>
<tr><td>មតិអង្គភាពណែនាំ</td><td colspan="6"></td></tr>
<tr><td>ហត្ថលេខា</td><td colspan="3"></td><td>កាលបរិច្ឆេត</td><td colspan="2"></td></tr>
</table>